# មេរៀនទី ៩៣៖ សាំសុនទទួលបានកម្លាំងពីព្រះជាម្ចាស់

## ពួកចៅហ្វាយ ១៥៖៩-១៦, ១៦៖៤-៣០

**មេរៀនសម្រាប់គ្រូ** ( *យូធូបលីង* )៖ https://youtu.be/cS2FbDVgqwg

**រឿងនៅក្នុងព្រះគម្ពីរសម្រាប់កុមារ៖** https://youtu.be/suV0nFSXLaE

**គោលបំណង៖** ព្រះបានប្រទានអំណោយទានដល់មនុស្សគ្រប់ៗគ្នា។

**ខគម្ពីរចងចាំ៖ ២ កូរិនថូស ៩៖១៥** *"អរព្រះគុណដល់ព្រះអង្គដោយព្រោះអំណោយទានទ្រង់ដ៏ រកថ្លៃងពុំបាន។"*

**ចំរៀង** ( *យូធូបលីង* )៖

១. ព្រះអង្គនៃយើងទ្រង់ខ្លាំងពូកែ https://youtu.be/VvrF94VKKHA

២.ព្រះយើងជាព្រះអស្ចារ្យ https://youtu.be/TU6HfxJXLvQ

៣.ខ្ញុំអាចធ្វើគ្រប់ការ https://youtu.be/RAti7KCmlvM

### ១. អធិស្ឋាន

### ២. ចំរៀង ( *រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស* )

### ៣. ល្បែងកំសាន្ត «សាំសុន ខ្លា ស្រីស្អាត»



១. កុមារត្រូវធ្វើកាយការខុសៗគ្នាដើម្បីលេងល្បែងនេះ។

២. សាំសុន៖កុមារត្រូវលើកដៃក្ដាប់ទាំងពីរ ហើយបង្ហាញ សាច់ដុំរបស់ពួកគេ។

៣.ខ្លា៖កុមារត្រូវលើកដៃទាំងពីររបស់ពួកគេ ហើយធ្វើដូចជាខ្លាគ្រហឹម ហើយដាក់ដៃនៅជិតត្រចៀករបស់ពួកគេ។ ឲ្យកុមារហាមាត់ ដើម្បីបង្ហាញធ្មេញរបស់ពួកគេ។





៤. ស្រីស្អាត៖ កុមារត្រូវលើកដៃចង្អុលរបស់ពួកគេហើយដាក់វានៅលើថ្ពាល់ ហើយធ្វើចរិតស្រីស្អាត។

៥. ចែកកុមារជាពីរក្រុមហើយឲ្យពួកគេឈរបែរខ្នងដាក់គ្នា។

៦. ក្រុមនីមួយៗត្រូវធ្វើការពិភាក្សាថាពួកគេត្រូវធ្វើកាយវិការមួយណា (សាំសុន ខ្លា ឬក៏ស្រីស្អាត)។

៧. គ្រូត្រូវប្រាប់កុមារថា(សាំសុនឈ្នះខ្លា).(ខ្លាឈ្នះស្រីស្អាត).(ស្រីស្អាតឈ្នះសាំសុន)

៨.នៅពេលដែលគ្រូរាប់ ១ ២ ៣ កុមារទាំងពីរក្រុមត្រូវបែរមុខមករកគ្នាហើយបង្ហាញពីកាយវិការរបស់ពួកគេ។ ប្រសិនបើក្រុមទាំងពីរធ្វើកាយវិការដូចគ្នា សូមឲ្យពួកគេលេងម្ដងទៀត។

៩. ប្រសិនបើក្រុមណាឈ្នះបីដងនោះក្រុមគេនឹងឈ្នះល្បែងនេះ។

១០. បន្ទាប់ពីលេងល្បែងនេះចប់សូមពន្យល់កុមារថា ថ្ងៃនេះយើងនឹងរៀនពី សាំសុនដែលមានកំលាំងខ្លាំង ហើយអាចយកឈ្នះគ្រប់ការទាំងអស់ ដោយសារតែគាត់ទទួលបានអំណាចមកពីព្រះ។

### ៤. ការណែនាំមេរៀន

តើអ្នកណាចូលចិត្តទទួលបានអំណោយ? តើអំណោយអ្វីខ្លះដែលអ្នកចង់បាន?(សូមឲ្យកុមារឆ្លើយ)។ តើអ្នកដឹងទេថា ព្រះប្រទានអំណោយទានដ៏ពិសេសឲ្យមនុស្សគ្រប់គ្នា? ត្រូវហើយព្រះបានធ្វើការនេះ!

ព្រះបានប្រទានអំណោយទានឲ្យមនុស្សគ្រប់គ្នា ពីព្រោះព្រះអង្គមានការងារសំរាប់មនុស្សគ្រប់គ្នាធ្វើ។ មានអ្នកខ្លះពូកែខាងរត់ប្រណាំង លោតកម្ពស់ និងឡើងភ្នំ ហើយមានអ្នកខ្លះទៀតពូកែខាងនិទានរឿង។ អ្នកខ្លះទៀត ពូកែខាងច្រៀង និងលេងភ្លេង។ ព្រះប្រទានអំណោយឲ្យមនុស្សគ្រប់ៗគ្នា ប៉ុន្តែអំណោយទានទាំងអស់នោះខុសៗគ្នា។ ថ្ងៃនេះយើងនឹងអានព្រះគម្ពីរដែលនិយាយពីសាំសុន។ ព្រះមានការងារពិសេសសំរាប់សាំសុនធ្វើ ហើយព្រះអង្គបានប្រទានអំណោយទានដ៏អស្ចារ្យដល់គាត់!

## ៥. រឿងនៅក្នុងព្រះគម្ពីរ

នៅក្នុងព្រះគម្ពីរថ្ងៃនេះ ជនជាតិអ៊ីស្រាអែលមិនស្តាប់បង្គាប់ព្រះម្តងទៀត ហើយជនជាតិភីលីស្ទីនជាអ្នកដែលត្រួតត្រាលើជនជាតិអ៊ីស្រាអែល ជាជនជាតិដែលបានប្រព្រឹត្តអាក្រក់ដាក់ពួកគេ។ ព្រះចង់សង្គ្រោះជនជាតិអ៊ីស្រាអែល និងចង់ឲ្យនរណាម្នាក់ចាប់ផ្តើមមកជួយរាស្ត្ររបស់ទ្រង់ឲ្យមានសេរីភាព ចេញពីមនុស្សអាក្រក់ទាំងអស់នោះ។

ព្រះបានប្រទានកូនដ៏ពិសេសម្នាក់ឲ្យទៅគូរស្វាមីមួយគូរ។ បុរសម្នាក់នោះ និងភរិយា របស់គាត់ចង់បានកូនជាខ្លាំង ហើយគាត់ទាំងពីរសប្បាយចិត្តណាស់ នៅពេលដែលព្រះប្រទានកូនដ៏ពិសេសនោះមកឲ្យពួកគេ។ ពួកគេបានដាក់ឈ្មោះកូននោះថា **សាំសុន**។ ព្រះចង់ឲ្យពួកគេចិញ្ចឹមកូនម្នាក់នេះតាមវិធីដ៏វិសេសមួយ ដូច្នេះនៅពេលដែលគាត់ធំឡើង គាត់អាចធ្វើការដ៏ពិសេសតាមអ្វីដែលព្រះត្រូវការឲ្យគាត់ធ្វើ។

ព្រះបានប្រាប់ឪពុកម្តាយថា ក្មេងប្រុសម្នាក់នេះមិនត្រូវផឹកស្រា និងមិនត្រូវឲ្យគាត់កាត់សក់ដាច់ខាត។ នេះហើយជាអ្វីដែលអ្នកផ្សេងទៀត នឹងស្គាល់គាត់ថាជាមនុស្សពិសេសរបស់ព្រះ។ ព្រះចង់ឲ្យសាំសុន ជួយដោះរាស្ត្ររបស់ទ្រង់ឲ្យមានសេរីភាពចេញពីជនជាតិភីលីស្ទីនដ៏អាក្រក់ទាំងនោះ។

ព្រះមានអំណោយទានដ៏ពិសេសសំរាប់សាំសុនពេលដែលគាត់ធំឡើង ដូច្នេះហើយគាត់អាចនឹងចាប់ផ្តើមដេញជនជាតិភីលីស្ទីនទាំងអស់នោះបាន។ ព្រះបានបង្កើតសាំសុនមកឲ្យមានកំលាំងដ៏ខ្លាំងខ្លា។សាំសុនខ្លាំងណាស់ នៅពេលដែលសត្វតោលោតមកសង្គ្រប់លើគាត់ សាំសុនអាចនឹងវាយ និងសម្លាប់តោនោះបាន នេះហើយជាអំណោយទានដ៏ពិសេស! ពួកភីលីស្ទីនមិនសប្បាយចិត្តដែលសាំសុន មានកម្លាំងខ្លាំងក្លាបែបនេះទេ។ ថ្ងៃមួយពួកភីលីស្ទីនបានព្យាយាមចាប់សាំសុន ដោយយកខ្សែមកចង គាត់ជាច្រើនជាន់។ ប៉ុន្តែសាំសុនបានធ្វើឲ្យខ្សែនោះដាច់ទាំងអស់យ៉ាងងាយ ដូចជាគេទាញអំបោះផ្តាច់អ៊ីចឹង។

ព្រះបានប្រទានអំណោយទានឲ្យគាត់មានកម្លាំងដ៏អស្ចារ្យ ដូច្នេះគាត់អាចនឹងធ្វើការដ៏ធំដែលព្រះចង់ឲ្យគាត់ធ្វើ ដោយទៅរំដោះឲ្យប្រជានជនអ៊ីស្រាអែលចេញពីពួកភីលីស្ទីន។ ហើយគាត់បានធ្វើការនោះ! គាត់អាចប្រើអំណោយទានដ៏ពិសេសរបស់គាត់ ទៅជួយរំដោះជនជាតិអ៊ីស្រាអែលឲ្យមានសេរីភាពពីពួកភីលីស្ទីន!

ក៏ដូចជាអំណោយទានដ៏ពិសេស ដែលព្រះបានប្រទានដល់សាំសុនដើម្បីធ្វើការដ៏អស្ចារ្យនោះ ព្រះទ្រង់ក៏បានប្រទានអំណោយទានដល់យើងគ្រប់គ្នាដែរ។ នេះក៏ព្រោះតែព្រះមានកិច្ចការឲ្យយើងគ្រប់ៗគ្នាធ្វើ។ អ្នកមិនចាំបាច់រងចាំរហូតដល់ក្លាយជាមនុស្សធំទេ។ អ្នកអាចប្រើអំណោយទានរបស់អ្នកក្នុងការបម្រើព្រះចាប់ពីពេលនេះបាន។

## ៦. សំនួរពិភាក្សា

១. តើអំណោយពិសេសអ្វីដែលព្រះបានប្រទានដល់សាំសុន? *(កម្លាំង គាត់អាចប្រយុទ្ធជាមួយសត្វតោដោយខ្លួនឯងបាន)*

២. តើព្រះមានការងារអ្វីសម្រាប់សាំសុន? *(រំដោះជនជាតិអ៊ីស្រាអែលពីពួកភីលីស្ទីន)*

៣. តើអ្នកគិតថាព្រះមានការងារអ្វីខ្លះសម្រាប់អ្នកឥឡូវនេះ? ហើយតើព្រះបានប្រទានអំណោយទានអ្វីខ្លះដល់អ្នកដើម្បីធ្វើការងារនេះ? *(ឱ្យកុមារឆ្លើយ)*

### ៧. ល្បែងកំសាន្ត «អ្នកណាខ្លាំងជាង»



១.ចែកកុមារជាពីរក្រុមស្មើគ្នា ហើយជ្រើសរើសមេក្រុមម្នាក់មួយ

២.គូសបន្ទាត់នៅចន្លោះកណ្តាល (អាចប្រើខ្សែ ឬស្កុតក៏បាន)



៣.មេក្រុមទាំងសងខាងស្រាក់ដៃគ្នា ហើយកូនក្រុមទាំងអស់ត្រូវតោងចង្កេះមេក្រុមបន្ត បន្ទាប់គ្នា

៤. ពេលគ្រូរាប់ ១ ២ ៣ ក្រុមនីមួយៗត្រូវប្រើកម្លាំងទាញគ្នាទៅវិញទៅមក

៥. ក្រុមណាដែលអាចទាញមេក្រុមណាមួយឲ្យឆ្លងផុតគំនូសកណ្តាលបាន ក្រុមនោះនឹងឈ្នះល្បែងនេះ។

៦. បន្ទាប់ពីលេងល្បែងនេះចប់ សូមពន្យល់កុមារថា យើងអាចនឹងរឹងមាំជាងមុនបានដោយសារការចេះជួយគ្នាទៅវិញទៅមក ហើយយើងអាចធ្វើអ្វីក៏បាននៅពេលដែលយើងទទួលបានកំលាំងពីព្រះ។

### ៨. ខគម្ពីរចងចាំ

**២កូរិនថូស ៩:១៥** *"អរព្រះគុណដល់ព្រះអង្គដោយព្រោះអំណោយទានទ្រង់ដ៏រកថ្លែងពុំបាន។"*

### ៩. ហាត្ថកម្ម

ឲ្យកុមារផាត់ព៌ណ "សាំសុនទទួលបានកម្លាំងពីព្រះជាម្ចាស់"

- សូមបោះពុម្ពរូបភាពនៅទំព័រខាក្រោម។

### ១០. ចំរៀង *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

### ១១. អធិស្ឋាន

**ការថ្វាយបង្គំសំរាប់គ្រូ៖ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន)**
ជាការអស្ចារ្យដែលយើងមានមិត្តសម្លាញ់នៅក្នុងព្រះយេស៊ូវ! នៅពេលដែលយើងដឹងថាយើងធ្វើអ្វីមួយខុស ហើយយើងសារភាពកំហុសនោះទៅកាន់ព្រះ ទ្រង់តែងតែគង់នៅជាមួយហើយអត់ទោសឲ្យយើង។ ហើយនៅពេលដែលយើងប្រឹងប្រែងសំរាប់ព័ន្ធកិច្ចរបស់ព្រះអង្គ ទ្រង់ក៏អាចធ្វើការដ៏អស្ចារ្យតាមរយៈយើងដែរ។ សាំសុនមានកម្លាំងខ្លាំងក្លាដែលមិនគួរឲ្យ ជឿ ដែលព្រះចាប់ផ្តើមប្រើប្រាស់កម្លាំងនោះសំរាប់ព័ន្ធកិច្ចរបស់ទ្រង់។ ប៉ុន្តែបន្ទាប់មកសាំសុនបាន ធ្វើខុសចំពោះព្រះ ហើយឈប់យកចិត្តទុកដាក់ចំពោះព្រះ! តើនៅពេលណាដែលអ្នកមានអារម្មណ៍ថា អ្នកធ្វើខុសចំពោះព្រះ? តើកំហុសនោះវាធ្វើឲ្យប៉ះពាល់ក្នុងការបំរើព័ន្ធកិច្ចព្រះដោយរបៀបណា? ទោះបីជាអ្នកធ្វើខុសចំពោះព្រះ តែព្រះនៅតែអាចប្រើអ្នកដូចជាទ្រង់បានប្រើសាំសុនអញ្ចឹងដែរ។ អ្នកគ្រាន់តែត្រូវពឹងផ្អែកលើកម្លាំងរបស់ព្រះ ហើយប្រើអំណោយទានដែលព្រះបានប្រទានឲ្យអ្នកមកបំរើព្រះអង្គ។

# សាំសុនទទួលបានកម្លាំងពីព្រះជាម្ចាស់



សូមសរសេរខគម្ពីរចងចាំ: ______________________________

______________________________________________

______________________________________________